# សង្កាត់សាលារៀនអូកឡិនដ៍
# សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ

**ស្តីអំពីការពិនិត្យ និងការអនុម័តចុងក្រោយ នៃអភិបាលកិច្ច និងកិច្ចការរដ្ឋបាលនៃតំបន់រៀបចំគម្រោងការមូលដ្ឋានសំរាប់កម្មវិធីអប់រំពិសេស (SELPA), ផែនការលៃទុកមូលនិធិប្រចាំឆ្នាំ និងគម្រោងការបំរើសសេវាប្រចាំឆ្នាំ សំរាប់ឆ្នាំសិក្សា 2020-2021។**

**ជូនចំពោះភាគីពាក់ពាន់ទាំងអស់៖**

**សូមធ្វើការកត់ចំណាំទុក**ថា នៅថ្ងៃទី 24 ខែមិថុនា ឆ្នាំ 2020 ក្រុមប្រឹក្សាភិបាលនៃសង្កាត់សាលារៀនអូកឡិនដ៍ នៅក្នុងកិច្ចប្រជុំធម្មតារបស់ខ្លួន នឹងបើកសវនាការជាសាធារណៈមួយ ស្តីអំពីការពិនិត្យ និងការអនុម័តចុងក្រោយ នៃអភិបាលកិច្ច និងកិច្ចការរដ្ឋបាលនៃតំបន់រៀបចំគម្រោងការមូលដ្ឋានសំរាប់កម្មវិធីអប់រំពិសេស (SELPA), គម្រោងការលៃទុកមូលនិធិប្រចាំឆ្នាំ និងគម្រោងការបំរើសសេវាប្រចាំឆ្នាំ សំរាប់ឆ្នាំសិក្សា 2020-2021។

សវនាការសាធារណៈ នឹងត្រូវបានធ្វើនៅថ្ងៃទី 24 ខែមិថុនា ឆ្នាំ 2020 នៅម៉ោង 6:00 ល្ងាច ឬបន្ទាប់ពីម៉ោងហ្នឹងភ្លាមៗតែម្តង នៅក្នុងកិច្ចប្រជុំចាក់បញ្ចាំងតាមអ៊ិនធឺណិតរបស់ក្រុមប្រឹក្សាភិបាលតាមថ្ងៃខែឆ្នាំហ្នឹង ដោយអនុលោមតាមតម្រូវការនានាទាំងអស់ពាក់ពាន់នឹងជម្ងឺឆ្លង COVID-19 នៃមន្ត្រីសុខាភិបាលសាធារណៈប្រចាំខោណធីអាឡាមីដា ចាប់មានប្រសិទ្ធភាពពីថ្ងៃខែឆ្នាំហ្នឹង។

គោលបំណងនៃសវនាការសាធារណៈនេះ គឺដើម្បីប្រមូលមតិយោបល់ពីសាធារណជន អំពីគម្រោងការនានា និងដើម្បីធ្វើការកែសម្រួលដល់ផ្នែកណាមួយ ប្រសិនបើត្រូវការចាំបាច់។

គម្រោងការថតចម្លងមួយច្បាប់ នឹងត្រូវបានដាក់ឱ្យពិនិត្យមើល មុនពេលបើកសវនាការជាសាធារណៈតាមអ៊ិនធឺណិត នៅថ្ងៃទី 29 ខែឧសភា ឆ្នាំ 2020 នៅគេហទំព័រ http://www.ousd.org/domain/69។

s/ Kyla Johnson-Trammell
លេខាធិការ, ក្រុមប្រឹក្សាគ្រប់គ្រង
សង្កាត់សាលារៀនអូកឡិនដ៍